**ទឹក ប្រព័ន្ធអនាម័យ និងអនាម័យផ្ទាល់ខ្លួន**

- ការលាងដៃនឹងសាប៊ូ និងទឹកស្អាត គឺជាខ្សែការពារទីមួយ ប្រឆាំងនឹងជំងឺកូវីដ-១៩ ប៉ុន្តែមនុស្ស ២,២ រយលាន នាក់ ខ្វះលទ្ធភាពទទួលបានសេវាទឹកសុវត្ថិភាព និងអនាម័យ។ ការដោះស្រាយតម្រូវការទឹក ប្រព័ន្ធអនាម័យ និងអនាម័យផ្ទាល់ខ្លួនរបស់ប្រជាជនដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ រួមទាំងអ្នក ដែលមានទឹកប្រើប្រាស់មិនស្មើភាព និងមិនគ្រប់គ្រាន់ ជាពិសេស ស្ត្រី និងក្មេងស្រី គឺចាំបាច់ខ្លាំងណាស់ ដើម្បីធានាបាននូវភាពជោគជ័យជាសកលក្នុងការតស៊ូប្រឆាំងនឹងជំងឺកូវីដ-១៩។
- វិធានការបន្ទាន់ដែលអាចជួយឱ្យសម្រេចកិច្ចការនេះ រួមមាន ការហាមឃាត់ការកាត់ទឹកដល់អ្នកដែល មិនអាចបង់វិក្កយបត្រទឹក ផ្តល់ទឹក សាប៊ូ និងសម្ភារអនាម័យដោយមិនគិតថ្លៃ (ដូចជា តាមរយៈការចែក ចាយចល័តនៅក្នុងសហគមន៍ ដោយមិនមានអនាម័យគ្រប់គ្រាន់) សម្រាប់រយៈពេលនៃវិបត្តិដល់ប្រជា ជនដែលស្ថិតក្នុងភាពក្រីក្រ និងអ្នកដែលរងផលប៉ះពាល់ពីការលំបាកផ្នែកសេដ្ឋកិច្ចនាពេលខាងមុខ។